# សិលាចារឹកប្រាសាទត្រពាំងរុន K.៧០៥

## ១- ព័ត៌មានទូទៅ

សិលាចារឹកមួយផ្ទាំងនេះ មានប្រភពមកពីប្រាសាទត្រពាំងរុន ជាប្រាសាទដែលពុំមានព័ត៌មានច្រើននោះឡើយ។ ឈ្មោះរបស់ប្រាសាទនេះ ដូចគ្នានឹងប្រាសាទមួយទៀតដែលមានទីតាំងស្ថិតនៅក្នុងខេត្តសៀមរាប ហើយក៏ជាទីតាំងដើមរបស់សិលាចារឹកចុះលេខ K.៥៩៨ ផង[១] ។

អត្ថបទសិលាចារឹកនេះចារជាភាសាខ្មែរបុរាណ ចំនួន១១បន្ទាត់ នៅលើមេទ្វារខាងត្បូង[២] មានចុះកាលបរិច្ឆេទនាមហាសករាជឆ្នាំ៩២៤ ឬ៩៣៤ ត្រូវនឹងគ្រិស្តសករាជឆ្នាំ១០០២ ឬ១០១២។ ចំពោះកាលបរិច្ឆេទដែលចោទជាបញ្ហានេះ គឺដោយសារសំណៅតួលេខនៅលើសំណៅផ្តិត មានភាពមិនច្បាស់លាស់។ ករណីបែបនេះ គឺត្រូវពឹងផ្អែកលើរូបថតលើថ្ម ឬការពិនិត្យលើថ្ម ប៉ុន្តែយើងពុំមានរូបថតឬអាចទៅពិនិត្យលើថ្មផ្ទាល់បាននោះទេ។ ដូច្នេះ យើងមានតែប្រើវិធីសាស្ត្រជ្រើសរើសយកកាលបរិច្ឆេទមហាសករាជ ៩២៤ ឬ៩៣៤ នៅក្នុងសិលាចារឹកដទៃទៀត មកពិនិត្យមើល ថាតើនាកាលបរិច្ឆេទនោះមានរឿងអ្វីកើតឡើងខ្លះ? ជាលទ្ធផល សិលាចារឹកដែលមានចុះកាលបរិច្ឆេទនាមហាសករាជឆ្នាំ ៩២៤ មានចំនួន៥សិលាចារឹក គឺសិលាចារឹកព្រះនន្ទ ទឹកថា K. ៨៩ សរសេរជាភាសាខ្មែរ, សិលាចារឹកព្រះខាន់កំពង់ស្វាយ K. ១៦១ សរសេរជាភាសាសំស្ក្រឹត, សិលាចារឹកប្រាសាទត្រពាំងរពៅ K. ៦៩១ សរសេរជាភាសាខ្មែរ, សិលាចារឹកប្រាសាទអំពិល K. ៨១៧ សរសេរជាភាសាខ្មែរ និងសិលាចារឹកប្រាសាទដូនទូល K. ១១៨៩ សរសេរជាភាសាខ្មែរ។ ចំណែកឯសិលាចារឹកប្រាសាទបន្ទាយព្រាវ K. ២២០ ក៏មានបញ្ហាដូចសិលាចារឹកត្រពាំងរុននេះដែរ។

តាមសេចក្តី នៅក្នុងសិលាចារឹកព្រះនន្ទទឹកថា នាមហាសករាជឆ្នាំ ៩២៤ មានព្រះគម្តែងអញកគវនៃព្រះនាមព្រះគម្តែងអញស្រីប្រថិវិន្ទ្របណ្ឌិត ស្រុកនៅឯរមនិ(រមណី)

[១] Cœdès, 1953

[២] CIK-EFEO, 2023

អត្ថបទដោយៈ ហ៊ុន ឈុនតេង

បានថ្វាយអាស្រមស្រីកទ្រេសូរ ចំពោះព្រះបាទកម្តែងកំដូនអញស្រីសូយ៌្យវម៌្មទេវ (សូរ្យវរ្ម័នទី១)។ ក្នុងសិលាចារឹកព្រះខាន់កំពង់ស្វាយ បានបញ្ជាក់ថានៅមហាសករាជឆ្នាំ ៩២៤ ត្រូវនឹងគ្រិស្តករាជឆ្នាំ ១០០២ គឺជាឆ្នាំដែលព្រះបាទស្រីសូយ៌្យវម៌្មទេវទី១ បានឡើងសោយរាជ្យសម្បត្តិ។ ឯក្នុងសិលាចារឹកប្រាសាទត្រពាំងរពៅវិញ នាកាលបរិច្ឆេទនោះ លោញទាន បានស្ថាបនាព្រះភ្ញើង និងជូនខ្ញុំបម្រើប្រុសដល់អាស្រមនេះ ពោលគឺជាសិលាចារឹកពុំទាក់ទងនឹងព្រះមហាក្សត្រនោះឡើយ។ ចំណែកសិលាចារឹកប្រាសាទអំពិលវិញ ផ្ទៃអត្ថបទ សឹករេចរឹល នាំឱ្យបាត់បង់សេចក្តីខ្លះ ប៉ុន្តែយើងអាចដឹងថានិយាយអំពីការធ្វើបុណ្យរបស់ព្រះកម្តែងតោកផ្វាង និងក្រុមគ្រួសារ ព្រមទាំងនិយាយពាក់ព័ន្ធនឹងតង្វាយរបស់ព្រះមហាក្សត្រ ដែលទំនងជាព្រះបាទស្រីសូយ៌្យវម៌្មទេវទី១។ យើងពុំមានអត្ថបទសិលាចារឹកប្រាសាទដូនទួល សម្រាប់ផ្ទៀងផ្ទាត់អត្ថន័យនោះឡើយ។

សេចក្តីក្នុងអត្ថបទសិលាចារឹកខាងលើ ដែលមានចុះកាលបរិច្ឆេទមហាសករាជឆ្នាំ ៩២៤ មានសេចក្តីទាក់ទងទៅនឹងព្រះបាទស្រីសូយ៌្យវម៌្មទេវទី១ ចំនួន៣។ ឯសិលាចារឹកដែលលោក ហ្សក សេដែស សិក្សាកន្លងមកដែលយល់ថាអាចត្រូវនឹងមហាសករាជឆ្នាំ ៩៣៤ មានចំនួន២ គឺសិលាចារឹកប្រាសាទបន្ទាយព្រាវ និងសិលាចារឹកប្រាសាទត្រពាំងរុននេះ។ យ៉ាងនេះក្តី អំណានកាលបរិច្ឆេទនោះ មិនជ្រះស្រឡះនោះទេ។

បើមើលសេចក្តីរបស់សិលាចារឹកត្រពាំងរុននេះ នាមហាសករាជឆ្នាំ៩២៤ ជាឆ្នាំដែលព្រះករុណាព្រះបាទស្រីសូយ៌្យវម៌្មទេវទី១ បានប្រទានដីស្រុកកម្រពង្វិដល់ព្រះកម្តែងអញតបស្វីន្ទ្របណ្ឌិត។ ដូច្នេះ កាលបរិច្ឆេទក្នុងសិលាចារឹកនេះ គួរតែជាមហាសករាជឆ្នាំ ៩២៤ ពុំមែន ៩៣៤ ទេ ដោយហេតុថានាឆ្នាំដែលព្រះបាទសូយ៌្យវម៌្មទេវទី១ ឡើងសោយរាជ្យសម្បត្តិ ព្រះអង្គទំនងជាបានធ្វើបុណ្យតាមរយៈព្រះរាជប្រទាននានា ប្រទានដល់មន្ត្រីសាសនា និងប្រាសាទនានា។ នេះ ជាព្រឹត្តិការណ៍គួរឱ្យកត់សម្គាល់មួយ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## ២- អត្ថបទដើមជាភាសាខ្មែរទំនើប

១- ៙៩២៤គកនុធ្វូលិវ្រះបាទកម្រតេង៑កំត្វនិអញ៑ត្រីសូយ៌្យវម៌្មទេវ

២- ឱយិប្រសាទស្រុកិកម្រព្វង្វិ[3]តវ្រះកម្រតេង៑អញ៑តបស្វីន្ទ្របន្ទិត

៣- មន្ទានិវ្រះករុណាបិសំន[4]ហិតវេគតគិបូជាទេវតាក្សេត្រវ្រសាជ[5]

៤- បុន្យបុន្យសាធកាចាយ៌្យផោង៑រិតគ្ងន្យតិបន្ទ្វលិប្រេវទ្វេ៑រិង៑គិបិវ្រ

៥- ◌ះកម្រតេង៑អញ៑តបស្វីន្ទ្របន្ទិតតំគលស្រេវ្រះវិង៑រុតតេលិ៙ភា

៦- គខ្នេតិទំនបិថ្មីគត១កន្ស្យង៑ស្នាង៑គត១ត្រៅវៅំគត១តីត្តុត២០-១០ខោលិ

៧- ៤០ទំនបិថ្កុ២០-១០៙ភាគណ្នោ៌ចិជ្រែករិគត១កន្ស្យង៑ស្នាង៑កវៅំគត១

៨- ត្រៅវៅំគត១តីត្តុតិ២០-១០ហរនាថ៤០ទំនបិមេបិតិ២០-១០ផ្សំមប្រតិប[6]

៩- ក្បស្រូស្វិកិ២នៅគេតនុថ្វេបិទៃតិលេង៑កល្បនាតពោះហនេះហគេ

១០- ស្វេយិនរកអំវលន្ស្ឫ្ទផោង៑តរាបិចន្ទ្រាទិត្យរិតអាចិបរិបាល

១១- នគេស្វេយិទិវ្យលោកអំវលនុគណាផោង៑៙ឱនមគ្គិវាយ៙

## ៣- អត្ថបទប្រែសម្រួល

(១-២) មហាសករាជឆ្នាំ៩២៤ នូវធូលីព្រះបាទគម្តែងកំដូនអញស្រីសូយ៌្យវម៌្មទេវ(ទី១) ប្រទានស្រុកកម្រព្វង្វិដល់ព្រះគម្តែងតបស្វីន្ទ្របណ្ឌិត។

(៣-៤) មាន(ព្រះរាជសាសន៍)ព្រះករុណាបីរួមផ្សំនាទីដ៏មានប្រយោជន៍ គឺសម្រាប់បូជាទេវតាក្សេត្រ/ទេវាល័យ ដែលទ្រង់ព្រះរាជទានព្រះបុណ្យ (ដល់)បុណ្យរបស់អាចារ្យទាំងឡាយ។

---

[3] លោក សេដែស អានជា «កម្រញិង៑»។

[4] ពាក្យត្រឹមត្រូវ គួរតែជា «សំនា»។

[5] ពាក្យត្រឹមត្រូវ គួរតែជា «ប្រសាទ»។

[6] សំណេរអាចប្រឡំ «ម្រតិប»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

(៤-៥) រី(បុណ្យគ្រាមុន)ដែលសូន្យ(អស់ទៅហើយ) ទ្រង់ត្រាស់បន្ទូលប្រើឱ្យចម្រើន (បុណ្យ)នោះឡើងវិញ (គឺ)គប្បីព្រះគម្តែងអញតបស្វីន្ទ្របណ្ឌិតតម្កល់ស្រែព្រះឡើងវិញ ឱ្យដូចដើមដដែល។

(៥-៧) ភាគខែខ្នើត (គឺស្រែ) ទំនប់ថ្មី (ស្រូវចំនួន)១០០, (ស្រែ)គង្គីងស្នាំង (ស្រូវចំនួន) ១០០, (ស្រែ)ត្រាវពៅំ (ស្រូវចំនួន)១០០, (ស្រែ)តិត្តុត (ស្រូវចំនួន)៣០, (ស្រែ)ខោល (ស្រូវ ចំនួន)៤០, (ស្រែ) ទំនប់ថ្កូវ (ស្រូវចំនួន)៣០។

(៧-៨) ភាគខែរនោច (គឺស្រែ)ជ្រែករី (ស្រូវចំនួន)១០០, (ស្រែ)គង្គីងស្នាំងក្រោម (ស្រូវចំនួន)១០០, (ស្រែ)ត្រាវពៅំ (ស្រូវចំនួន)១០០, (ស្រែ)តិត្តុត (ស្រូវចំនួន)៣០, (ស្រែ) ហរនាថ (ស្រូវចំនួន)៤០, (ស្រែ) ទំនប់មេបិត (ស្រូវចំនួន)៣០។

(៨-៩) ផ្សំទាំងខែខ្នើតនិងរនោច ស្រូវចំនួន២ស្លឹក។

(៩-១១) នៅនរូជនណាដ៏ធ្វើទីទៃឬបោះបង់រណ្តាប់បូជាទាំងនេះ នរូជននោះនឹង សោយនរកច្រើនក្រៃ ព្រមទាំងគ្រួសារញាតិមិត្តផង ដរាបណាព្រះចន្ទ្រនិងព្រះអាទិត្យ (នៅតែមាន)។ រីនរូជនណាដែលអាចថែរក្សា(រណ្តាប់បូជាទាំងនេះបាន) នរូជននោះ (សូមបាន)សោយនូវទិព្វលោកដ៏ច្រើនក្រៃណា ព្រមទាំងគ្រួសារញាតិមិត្តផង។ ឱម! ខ្ញុំ សូមនមស្ការចំពោះព្រះឥសូរ!

### ៤- សរុបសេចក្តី

អត្ថន័យសិលាចារឹកនេះ គឺជាព្រះរាជប្រទានរបស់ព្រះបាទស្រីសូរ្យវម៌្មទេវទី១ ប្រទានស្រុកកម្រព្ទង្វិដល់ព្រះគម្តែងតបស្វីន្ទ្របណ្ឌិត។ ទ្រង់ក៏បានត្រាស់ឱ្យរៀបចំរណ្តាប់ បូជាគ្រាមុនដែលសូន្យវិនាសអស់ទៅហើយនោះ ឱ្យរស់ពនឡើងវិញ។ បន្ទុកនេះ ធ្លាក់ទៅ លើព្រះគម្តែងអញតបស្វីន្ទ្របណ្ឌិត ជាអ្នករៀបចំ ពោលគឺរៀបចំចាត់ចែងផលស្រូវ សម្រាប់ផ្គត់ផ្គង់វេនខ្នើតនិងរនោច។ ចុងក្រោយ គឺជាពរនិងបណ្តាសា។ ពាក្យផ្តាសាមាន ដល់នរណាដែលពុំរៀបចំឬបំផ្លាញរណ្តាប់បូជានោះឱ្យធ្លាក់នរកនានា រួមទាំងគ្រួសារ

ដរាបណាព្រះចន្ទនិងព្រះអាទិត្យនៅតែមាន នៅតែស្ថិតក្នុងនរកនោះដដែល។ ឯពរវិញ មានដល់នរណាដែលរក្សារណ្ដាប់បូជាឬបុណ្យនោះឱ្យគង់វង្ស នឹងបានសោយនូវទិព្វលោក រួមទាំងគ្រួសារផង។

## ៥- ពន្យល់ពាក្យ

| | |
|---|---|
| **ឱយិប្រសាទ** | ប្រទាន។ |
| **មន្នានិ** | < មនិ + មានិ = មាន។ |
| **ហិត** | (សំ.) ប្រយោជន៍។ |
| **វេគ** | (សំ.) និវេសន៍ លំនៅ...។ |
| **ទេវតាក្សេត្រ** | (សំ.) លំនៅទេវតា ទេវាល័យ ប្រាសាទ។ |
| **សាធកាចាយ៌្យ** | (សំ. សាធក + អាចាយ៌្យ) អាចារ្យអ្នកនាំឱ្យសម្រេច(បុណ្យ)។ |
| **វទ្ធ៌** | (សំ.) ចម្រើន។ |
| **តំគល** | តម្កល់ ដាក់ថ្កល់។ |
| **វុតតេលិ** | ដូចដដែល។ |
| **អំវល** | ច្រើន ច្រើនក្រៃ។ |
| **វ្ឫន្ទ** | (សំ.) គណ ក្រុម គ្រួសារ ញាតិមិត្ត។ |
| **បរិបាលន** | (សំ.) រក្សា។ |
| **ស្វេយិ** | សោយ។ |
| **ទិវ្យលោក** | (សំ.) ទិព្វលោក ស្ថានសួគ៌ ស្ថានទេវតា។ |

## ឯកសារយោង

CIK-EFEO (Producer). (2023). Télécharger l'Inventaire Excel mis à jour en 2023. Retrieved from https://cik.efeo.fr/inventaire-cik-des-inscriptions-khmeres/

Cœdès, George. (1953). Inscription de Pràsàt Trapăṅ Run. In *Inscription du Cambodge* (Vol. V, pp. 198-199). Paris: Editions de Boccard.

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## បញ្ជីរូបភាព



អត្ថបទចម្លងសិលាចារឹកប្រាសាទត្រពាំងរុន K.៧០៥

(ចម្លងដោយ៖ ហ៊ឹម ស្រីពៅ)



សំណៅផ្តិតសិលាចារឹកប្រាសាទត្រពាំងរុន K.៧០៩

(រូបថត៖ EFEO_ CAM17079)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង